ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤៣.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតដែនជម្រកសត្វព្រៃ«ភ្នំត្នោត-ភ្នំពក»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» ដែលមានផ្ទៃដីសរុបចំនួន ៤២.០៩៧ (បួនម៉ឺនពីរពាន់កៅសិបប្រាំពីរ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រ ស្រុកសង្គមថ្មី និងស្រុកគូលែន ខេត្តព្រះវិហារ និងស្រុកជីក្រែង ខេត្តសៀមរាប ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកាគោល( Datum: WGS1984 ) ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y |
| 1 | 444514 | 1499110 | 12 | 473777 | 1494570 | 23 | 454852 | 1482160 |
| 2 | 447408 | 1499070 | 13 | 472189 | 1489010 | 24 | 449973 | 1483810 |
| 3 | 447470 | 1497460 | 14 | 473903 | 1489230 | 25 | 450084 | 1487720 |
| 4 | 450226 | 1496440 | 15 | 473908 | 1485320 | 26 | 448473 | 1488750 |
| 5 | 450224 | 1498670 | 16 | 473060 | 1485420 | 27 | 446722 | 1488750 |
| 6 | 457017 | 1498820 | 17 | 471895 | 1484790 | 28 | 445756 | 1489540 |
| 7 | 457033 | 1499910 | 18 | 471049 | 1484190 | 29 | 445705 | 1491980 |
| 8 | 459907 | 1500610 | 19 | 469967 | 1483240 | 30 | 448144 | 1493320 |
| 9 | 460406 | 1498650 | 20 | 470686 | 1481860 | 31 | 448043 | 1494140 |
| 10 | 461556 | 1500840 | 21 | 463297 | 1481670 | 32 | 444515 | 1494110 |
| 11 | 472062 | 1496450 | 22 | 459385 | 1483030 | | | |

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ដើម្បីធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី សារព័នមជ្ឈដ្ឋានធម្មជាតិ ព្រមទាំងធានាឱ្យមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វព្រៃ រុក្ខជាតិ និងជីវៈចម្រុះ
- រក្សាលំនឹងបរិស្ថាន ការពារនិងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផល និងសេវាកម្មទេសចរធម្មជាតិសម្រាប់ការប្រើប្រាស់ដោយនិរន្តរភាព
- លើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាអ្នកពាក់ព័ន្ធក្នុងការថែរក្សាវប្បធម៌ ប្រពៃណី ក៏ដូចជាការការពារ អភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព។/

**មាត្រា៣ .-**

ផ្ទៃដីនៃអនុក្រឹត្យដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» នេះមិនរួមបញ្ចូលដីកម្មសិទ្ធិឯកជន និងដីប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

**មាត្រា៤ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្ត និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ច ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី ដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» ស្ថិតក្នុងខេត្តព្រះវិហារ និងខេត្តសៀមរាប

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៧




និយាមការគោល

| Id | X | Y |
|---|---|---|
| 1 | 444514 | 1499110 |
| 2 | 447408 | 1499070 |
| 3 | 447470 | 1497460 |
| 4 | 450226 | 1496440 |
| 5 | 450224 | 1498670 |
| 6 | 457017 | 1498820 |
| 7 | 457033 | 1499910 |
| 8 | 459907 | 1500610 |
| 9 | 460406 | 1498650 |
| 10 | 461556 | 1500840 |
| 11 | 472062 | 1496450 |
| 12 | 473777 | 1494570 |
| 13 | 472189 | 1489010 |
| 14 | 473903 | 1489230 |
| 15 | 473908 | 1485320 |
| 16 | 473060 | 1485420 |
| 17 | 471895 | 1484790 |
| 18 | 471049 | 1484190 |
| 19 | 469967 | 1483240 |
| 20 | 470686 | 1481860 |
| 21 | 463297 | 1481670 |
| 22 | 459385 | 1483030 |
| 23 | 454852 | 1482160 |
| 24 | 449973 | 1483810 |
| 25 | 450084 | 1487720 |
| 26 | 448473 | 1488750 |
| 27 | 446722 | 1488750 |
| 28 | 445756 | 1489540 |
| 29 | 445705 | 1491980 |
| 30 | 448144 | 1493320 |
| 31 | 448043 | 1494140 |
| 32 | 444515 | 1494110 |

ព្រះវិហារ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៧
អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ
អ៊ុន_ចាន់ដា

សៀមរាប, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៧
អភិបាល នៃគណៈអភិបាលខេត្តសៀមរាប
ឃឹម_ប៊ុនសុង

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងបរិស្ថាន
សាយ សំអាល់

**សញ្ញាសម្គាល់**

- ចំណុចនិយាមការ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- ផ្លូវ
- ទឹក
- ព្រំប្រទល់ដែនជម្រកសត្វព្រៃ ភ្នំត្នោត-ភ្នំពក

**គម្របព្រៃឈើឆ្នាំ២០១៤**

- ព្រៃស្រោង
- ព្រៃពាក់កណ្តាលស្រោង
- ព្រៃល្បោះ
- ព្រៃឫស្សី
- ចំការកៅស៊ូ
- ដីពុំមានគម្របព្រៃឈើ

ផ្ទៃដី ដែនជម្រកសត្វព្រៃ «ភ្នំ ត្នោត -ភ្នំពក» សរុប ៤២.០៩៧ ហិកតា